**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៣៤..សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ហៅកាត់ **គ.ស.ច.គ.** ដូចខាងក្រោម៖ ,/

១-សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធានអចិន្ត្រៃយ៍

៣-ឯកឧត្តម **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៤-ឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន

៥-លោកជំទាវ **មឹន មាណវី** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធាន

៦-ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធាន

៧-ឯកឧត្តម **ស៊ូ តិរិទ្ធ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨-ឯកឧត្តមវេជ្ជបណ្ឌិត **តែ គុយស៊ាង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៩-ឯកឧត្តម **អ៊ឹម កុច** រដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា សមាជិក

១០-ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១១-ឯកឧត្តម **ការ់ ម៉ន** រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១២-ឯកឧត្តម **ឯល វ៉ាន់សារ៉ាត** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១៣-ឯកឧត្តម **ខៀវ មុត** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

១៤-ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១៥-ឯកឧត្តម **ជា ម៉ូរ៉ា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១៦-លោកជំទាវ **ប្រាក់ ច័ន្ទណាយ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

១៧-ឯកឧត្តម **ម៉ែន សុផល** រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សមាជិក

១៨-ឯកឧត្តម **គឹម ឆូច** រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម សមាជិក

១៩-ឯកឧត្តមបណ្ឌិត**ឈន សុភាព** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២០-ឯកឧត្តម **អ៊ីវ ផល្លី** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

២១-ឯកឧត្តម **ចាន់ តារា** អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន សមាជិក

២២-ឯកឧត្តម **គឹម បូរី** អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ សមាជិក

២៣-លោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា សមាជិក

២៤-លោកឧត្តមសេនីយ៍ទោ **គួច ស៊ីអិន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក។

**ប្រការ ២.-**

**គ.ស.ច.គ.** ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យលេខ ៨៤ អនក្រ ប្រ.ក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

**ប្រការ ៣.-**

**បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។**

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ